**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍បាត់ដំបង

៚៚៚✲៛៛៛

សំណុំរឿងស៊ើបសួរ

លេខ: ១២៥

ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២

<u>សាលដីកា</u>

លេខ:១៣៧ (ខ)

ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

10. 10. 22

# <u>គោរពនាមប្រជារាស្ត្រខ្មែរ</u>

## <u>សាលាឧទ្ធរណ៍បាត់ដំបង</u>

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និង ព្រះរាជក្រឹត្យលេខ នស/រតក/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងស៊ើបសួរលេខ ១២៥ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ដែលមាន៖

-ជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៣ឆ្នាំ (កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩) ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកន្ទ្រក ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មុខរបរ រកស៊ីចងការប្រាក់ នៅលីវ ឪពុកឈ្មោះ ឆេន ពេក (រ) ម្តាយឈ្មោះ [redacted] (រ) កំរិតវប្បធម៌ ថ្នាក់ទី៥ ទោសពីមុន គ្មាន ។ (ក្នុងឃុំ) (អ្នកប្តឹងឧទ្ធរណ៍)



Scanned with CamScanner

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៨៨ យខ/ឌ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

<u>ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ:</u> មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅចំណុចភូមិតាភុលសង្កាត់ស្វាយដង្គំ ក្រុងសៀមរាបខេត្តសៀមរាបកាលពីថ្ងៃទី០៦ខែកក្កដាឆ្នាំ២០២២ ជាបទល្មើសដែលមានបញ្ញត្តិផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

មានលោក[redacted]ស្នួនិក ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] សុកថុក ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។

## <u>ដំណើររឿងហេតុមានដូចតទៅ</u>

កាលពីថ្ងៃទី ០៣ខែកក្កដាឆ្នាំ២០២២នៅចំណុចហាងកាហ្វេប្រោនស្ថិតនៅភូមិតាភុលសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មានករណី មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបានបង្កឡើយដោយជនសង្ស័យឈ្មោះ[redacted]ជាត ភេទប្រុស អាយុ២៣ឆ្នាំ ។ រឿងហេតុដំបូងមានឈ្មោះ[redacted]ជ្រក់ បានទៅខ្ចីលុយពីឈ្មោះ[redacted]សុកថុក ភេទប្រុស អាយុ ៤៩ឆ្នាំ ដោយឈ្មោះ[redacted] ជាត ជាអ្នកភ្ជាក់ងារកណ្តាលទទួលកំរៃជើងសារបានទៅជាមួយផងដែរ ។ នៅក្នុងប្រតិបត្តិការខ្ចីប្រាក់នេះ គឺមានកិច្ចសន្យាដោយឈ្មោះ[redacted]ជ្រក់ ជាអ្នកខ្ចីប្រាក់ (ដាក់បញ្ចាំបង្កាន់ដៃក្បាលដី) ឈ្មោះ[redacted] ប៉ង ជាបុគ្គលិក ក្រុមហ៊ុនកម្ចី បញ្ចាំ រំលោះ ប៊ីវីធូ លីហ្ស៊ីង និងជនសង្ស័យឈ្មោះ [redacted] ជាត ជាអ្នកធានាឱ្យឈ្មោះ[redacted]ជ្រក់ ដោយបានចេញមូលប្បទានប័ត្រមួយសន្លឹកលេខ ១៣៧១៥៣ របស់ធនាគារអេស៊ីលីដា ដែលមានទឹកប្រាក់ចំនួន ១៦,០៥០ ដុល្លាអាមេរិក ទៅឱ្យដើមបណ្តឹងឈ្មោ[redacted]សុកថុល ដើម្បីធានាថា នៅថ្ងៃកំណត់ទី០៦ ខែកក្កដា ឆ្នាំ២០២២ បើឈ្មោះ[redacted]ជ្រក់ មិនសងប្រាក់ឱ្យដើមបណ្តឹង[redacted] សុកថុក ទេ អាចទៅបើកប្រាក់តាមរយៈមូលប្បទានប័ត្រលេខ ១៣៧១៥៣ ប៉ុន្តែដល់ថ្ងៃកំណត់សងប្រាក់ ដើមបណ្តឹងឈ្មោះ[redacted] សុកថុល ពុំទទួលបានប្រាក់ដូចការសន្យាទេ ។ រហូតដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ដើមបណ្តឹងឈ្មោះ[redacted] សុកថុល បានយកមូលប្បទានប័ត្រមួយសន្លឹកលេខ ១៣៧១៥៣ ទៅបើក ស្រាប់តែខាងធនាគារអេស៊ីលីដា បានចេញលិខិតបង្វិលត្រឡប់មូលប្បទានប័ត្រមកវិញ ហើយបញ្ជាក់ថា មូលប្បទានប័ត្រលេខ ១៣៧១៥៣ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ គ្មានសាច់ប្រាក់ទេ (សំវិធានវត្ថុគ្មាន ឬមានមិនគ្រប់គ្រាន់) ។ ទើបដើមបណ្តឹងឈ្មោះ[redacted] សុកថុល សម្រេចដាក់ពាក្យបណ្តឹងចូលមកការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

**-បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ៨៦៨ ឧ.ជ.ស.ព ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

ឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទឈ្មោះ [redacted] ជាត ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានអត្តសញ្ញាណដូចខាងលើ (ក្នុងឃុំ)

ពីបទៈ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍ដែលអាចជួញដូរបាន ប្រព្រឹត្តនៅចំណុចភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ជាបទល្មើសដែលមានបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្ដីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

-បានឃើញ ពាក្យស្នើសុំដោះលែងឱ្យនៅក្រៅ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ស្ងួនិច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ជាត ។

**-បានឃើញ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ: ៩២៣ ជសព/ឧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖**

មិនព្រមដោះលែងឱ្យនៅក្រៅឃុំជនត្រូវចោទឈ្មោះ [redacted] ជាត ភេទប្រុស អាយុ២៣ឆ្នាំ (មានអត្តសញ្ញាណខាងលើ) ដែលត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាសម្រេចឃុំខ្លួន ៨៦៨ ឧជសព ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ។

-បានឃើញៈ ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ស្ងួនិច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ជាត សុំប្ដឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខៈ ៩២៣ ជសព/ឧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

-បានឃើញៈ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ។

-បានឃើញៈ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ។

## <u>នាពេលសវនាការ</u>

-ជនត្រូវចោទឈ្មោះ [redacted] ជាត (វត្តមាន)

-លោក [redacted] ស្ងួនិក ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុកថុក (អវត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនត្រូវចោទឈ្មោះ [redacted] ជាត បានឆ្លើយថា ខ្លួនប្ដឹងឧទ្ធរណ៍មកនេះ គឺខ្លួនស្នើសុំនៅក្រៅឃុំ ។ ឪពុកម្ដាយខ្លួនចាស់ៗ ខ្លួននៅផ្ទះខ្លួនឯង ខ្លួនក៏មានមុខរបរ ជាអ្នករងស៊ីលក់ទិញដី ។ ពេលដែលសមត្ថកិច្ច



Scanned with CamScanner

ឃាត់ខ្លួនខ្លួននោះ ខ្លួនបានព្យាយាមដោះស្រាយជាមួយដើមបណ្ដឹងរដ្ឋប្បវេណីដែរ ។ ចំពោះសែកដែលខ្លួនចេញនោះ គឺដើមបណ្ដឹងរដ្ឋប្បវេណីឱ្យខ្លួនចេញឱ្យគាត់ដើម្បីជានាទំនុកចិត្ត ។ ខ្លួនសំណូមពរ ឱ្យតុលាការដោះលែងខ្លួនឱ្យបាននៅក្រៅឃុំផង ។

**-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា** ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់លោក[redacted]ស្ទូនិច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ[redacted]ដាគ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។ តាមអង្គហេតុ ជនត្រូវចោទបានព្យាយាមដោះស្រាយជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ជនត្រូវចោទមានទីលំនៅមុខរបរច្បាស់លាស់ ។ តំណាងមហាអយ្យការ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាស៊ើបសួរសាលាឧទ្ធរណ៍បាត់ដំបងពិនិត្យ ពិចារណា សម្រេចតាមនីតិវិធីច្បាប់ ។

**-មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទបានធ្វើសេចក្តីសន្និដ្ឋានថា** នៅក្នុងរឿងនេះ កូនក្តីខ្លួនមានទីលំនៅច្បាស់លាស់ និងមានមុខរបរ រកស៊ីលក់ទិញដី ។ រឿងនេះ កូនក្តីខ្លួនដាក់ប្លង់ដើម្បីខ្ចីលុយគេ ហើយគេក៏ឱ្យកូនក្តីខ្លួនចេញសែកដើម្បីជានាលុយនោះ ។ ខ្លួនក្តីខ្លួនមានឪពុកម្ដាយចាស់ ដែលត្រូវមើលថែ ។ ហេតុនេះ ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចឱ្យកូនក្តីខ្លួនបាននៅក្រៅឃុំជាបណ្ដោះអាសន្ន ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនត្រូវចោទ
-ក្រោយពីបានស្ដាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
-ក្រោយពីបានស្ដាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ
-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ
-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សភាស៊ើបសួរនៃសាលាឧទ្ធរណ៍បាត់ដំបង</u>

## <u>យល់ឃើញថា</u>

១.ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់មេធាវី [redacted] ស្ទូនិក ធ្វើឡើងតាមកំណត់ច្បាប់ សភាស៊ើបសួរសាលាឧទ្ធរណ៍បាត់ដំបងទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.តាមបញ្ញត្តិមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាគោលការណ៍ជនត្រូវចោទតែមានសេរីភាព ។

៣.ជនត្រូវចោទមានទីលំនៅច្បាស់លាស់ ជនត្រូវចោទបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួររួចហើយ ការស៊ើបអង្កេតមានភាពជឿនលឿនហើយដែរ ហើយនៅក្នុងសំណុំរឿងនេះ ក៏ពុំមានភស្តុតាងណាផ្សេង និងជនសង្ស័យផ្សេងទៀត ដែលបារម្ភថា បើឱ្យជនត្រូវចោទនៅក្រៅឃុំ ជនត្រូវចោទទៅបំផ្លាញភស្តុតាង ឬត្រូវរ៉ូវគ្នាជាមួយជនសង្ស័យផ្សេងទៀតឡើយ ។ ដូច្នេះការអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន គឺពុំធ្វើឱ្យប៉ះពាល់ដល់នីតិវិធីរបស់តុលាការឡើយ ។ ម្យ៉ាងទៀតមកដល់ពេលនេះ នៅពុំទាន់មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់លើជនត្រូវចោទនៅឡើយទេ ។ ដូច្នេះ ប្រសិនបើសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នជាបន្តទៀត ហើយលទ្ធផលចុងក្រោយនៃការស៊ើបអង្កេតបង្ហាញថា គ្មានពិរុទ្ធភាពលើជនត្រូវចោទ នោះការឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ននេះ



Scanned with CamScanner

ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពបុគ្គលរបស់ជនត្រូវចោទ ។ ផ្ទុយទៅវិញ បើអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបណ្ដោះអាសន្ន ហើយលទ្ធផលចុងក្រោយនៃការស៊ើបអង្កេតបង្ហាញថា មានពិរុទ្ធភាពលើជនត្រូវចោទ ហើយតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារជនត្រូវចោទ នោះគេអាចអនុវត្តសាលក្រម ឬសាលដីកាស្ថាពរ ដោយចាប់ខ្លួនជនត្រូវចោទយកមកអនុវត្តការផ្ដន្ទាទោសជាក្រោយក៏បាន ។

៤.ដើម្បីធានានូវវត្តមានរបស់ជនត្រូវចោទចំពោះមុខតុលាការ គប្បីដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឱ្យការឃុំខ្លួនវិញ ។

៥.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្ដីសន្និដ្ឋានថា ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ស្លូនិច ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ [redacted] ផាត ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។តាមអង្គហេតុ ជនត្រូវចោទបានព្យាយាមដោះស្រាយជាមួយដើមបណ្ដឹងរដ្ឋប្បវេណី ជនត្រូវចោទមានទីលំនៅ មុខរបរច្បាស់លាស់ ។ តំណាងមហាអយ្យការ សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាស៊ើបសួរសាលាឧទ្ធរណ៍បាត់ដំបង ពិនិត្យ ពិចារណា សម្រេចតាមនីតិវិធីច្បាប់ ។

៦.ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៩២៣ ជសព/ឧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលសម្រេចសេចក្ដីមកនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដែលគប្បីបដិសេធចោលជាអសារបង់ ។

## ហេតុដូច្នេះទីនិច្ឆ័យសេចក្ដី

១/ ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ខែកញ្ញា ឆ្នាំ២០២២ របស់មេធាវី [redacted] ស្លូនិក ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២/ បដិសេធ ដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំសលេខ ៩២៣ ជសព/ឧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ចោលជាអសារបង់ ។

៣/ ឱ្យឈ្មោ[redacted]ផាត ភេទប្រុស អាយុ២៣ឆ្នាំ (កើតថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៩៩) ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកន្ទ្រក ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួនភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មុខរបរ រកស៊ីចងការប្រាក់ នៅលីវ ឪពុកឈ្មោះ [redacted] ពេក (រ) ម្ដាយឈ្មោះ[redacted]ញ៉ៅ (រ) កំរិតវប្បធម៌ ថ្នាក់ទី៥ ទោសពីមុន គ្មាន នៅក្រៅឃុំជាបណ្ដោះអាសន្ន ។

៤/ បង្គាប់ឱ្យសមត្ថកិច្ចធ្វើការដោះលែងឈ្មោះ [redacted] ផាត នេះ ចេញពីមន្ទីរឃុំឃាំងជាបន្ទាន់ ប្រសិនបើឈ្មោះនេះ មិនត្រូវជាប់ឃុំខ្លួនពីបទអ្វីផ្សេងទៀតទេ ។

៥/ ដាក់ឱ្យជនត្រូវចោទឈ្មោះ [redacted] ផាត ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយឱ្យឈ្មោះនេះ គោរពនូវកាតព្វកិច្ចមួយចំនួន ដូចខាងក្រោម៖

ក.មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ,

ខ.ត្រូវឆ្លើយតបទៅនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ,

គ.ត្រូវចូលទៅបង្ហាញខ្លួននៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មួយដង ក្នុង០១(មួយ)ខែ នៅសប្តាហ៍ទី១ នៃខែនីមួយៗ ។

បើជនត្រូវចោទរូបនេះ មិនគោរពតាមកាតព្វកិច្ចខាងលើនេះទេ ចៅក្រមស៊ើបសួរអាចចាប់ឃុំខ្លួនជនត្រូវចោទរូបនេះជាថ្មីបាន ។

-សាលដីកានេះ ប្រកាសជាអសាធារណៈ នាថ្ងៃ០៦ ខែតុលា ឆ្នាំ២០២២ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

បាត់ដំបង ,ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]